**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Nov-2012, 15:43
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូង បើកសវនាការជាសាធារណៈ និងយកភស្តុតាងទាក់ទងនឹងការអនុវត្តដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធរបស់ កសចស ស្តីពីការធ្វើសម្ភាសន៍សាក្សីដោយគ្មានការថតសម្លេង"**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

លោក គង់ សំអុន
Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- ចាប់តាំងពីចាប់ផ្តើមសវនាការ មេធាវីការពារក្តី អៀង សារី បានដាក់សំណើចំនួន៣ ដោយចោទប្រកាន់ពីនីតិវិធីមិនសមស្របនៅក្នុងការសម្ភាសន៍ជាមួយនឹងសាក្សីមួយចំនួន ក្នុងអំឡុងពេលស៊ើបអង្កេតរបស់តុលាការ ក្នុងសំណុំរឿងលេខ០០២[1]។ សហព្រះរាជអាជ្ញាបានបដិសេធការទាមទារទាំងនេះ ហើយសហព្រះរាជអាជ្ញាបានសន្និដ្ឋានថា មេធាវីការពារក្តីខកខានមិនបានបង្ហាញភាពមិនប្រក្រតីនីតិវិធីណាមួយទេ ឬផលប៉ះពាល់លើសិទ្ធិរបស់ អៀង សារី ទទួលបានសវនាការត្រឹមត្រូវទេ[2]។

២- កាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១២ ភាគីបានទទួលដំណឹងថា មេធាវីការពារក្តីបានដាក់សំណើភ្លាមៗជូនទៅអង្គជំនុំជម្រះសាលាដំបូង សុំឱ្យបើកកិច្ចស៊ើបសួរ និងបើកសវនាការជាសាធារណៈមួយពាក់ព័ន្ធនឹង "ការអនុវត្តដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ ក្នុងការធ្វើសម្ភាសន៍សាក្សី ដោយមិនមានថត

---

[1] ឯកសារលេខ **E221** សំណើរបស់ អៀង សារី សុំស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីរ របស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកថា ជាការលេងល្បិចឆ្អែក, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២; ឯកសារលេខ **E224** សំណើរបស់ អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសំឡេងនានា ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២; ឯកសារលេខ **E234** សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឱ្យ ក.ស.ច.ស ធ្វើការបញ្ជាក់ ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ឱ្យផ្តល់ភស្តុតាង ទាក់ទងនឹងការស្តាប់ចម្លើយនេះ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១២។

[2] ឯកសារលេខ **E221/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើឱ្យស្តាប់ការបង្ហាញភស្តុតាងពីអ្នកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីរ ធ្វើឡើងដោយ ក.ស.ច.ស, ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១២; ឯកសារលេខ **E224/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសំឡេងនានា ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨", ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១២ (សហព្រះរាជអាជ្ញាពុំមានជំទាស់ទៅនឹងសំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកព័ត៌មានបន្ថែមពី ក.ស.ច.ស ទេ); ឯកសារលេខ **E234/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឱ្យ ក.ស.ច.ស ធ្វើការបញ្ជាក់ ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ឱ្យផ្តល់ភស្តុតាង ទាក់ទងនឹងការស្តាប់ចម្លើយនេះ", ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២។

សម្តែងជាមួយនឹងសាក្សីមួយចំនួន"[3] ("សំណើ")។ មេធាវីការពារក្តីបានចោទប្រកាន់ថា សំណើរបស់ពួកគេ "ត្រូវតែធ្វើចាំបាច់ ពីព្រោះមេធាវីការពារក្តីបានរកឃើញនាពេលថ្មីៗនេះ មានករណីចំនួន១២ (ក្រៅពីករណីដែលបានចង្អុលបង្ហាញដោយមេធាវីការពារក្តីនៅក្នុងសំណើមួយចំនួនកន្លងមក និងដោយមេធាវីការពារក្តីផ្សេងទៀត) ដែលនៅក្នុងនោះ អ្នកស៊ើបអង្កេតរបស់ កសចស បានធ្វើសម្ភាសន៍សាក្សីដោយគ្មានការថតសម្លេង[4]"។ សំណើនេះបានបន្តធ្វើការប៉ុនប៉ងបង្ហាញឲ្យឃើញថា ការប្រព្រឹត្តិដែលបានចោទប្រកាន់របស់អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយមិនបានថតសម្លេង ឬមិនបានធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរអំពីការសន្ទនាជាមួយសាក្សី គឺជាការរំលោភលើវិធានផ្ទៃក្នុង ហើយហេតុដូចនេះគឺជាការរំលោភទៅលើសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ។ ជាដំណោះស្រាយ មេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការជាសាធារណៈមួយ "ដើម្បីស៊ើបអង្កេតលើការអនុវត្តរបស់ កសចស ក្នុងការសម្ភាសន៍សាក្សី ដោយពុំបានថតសម្លេង និងអានុភាពអាចមានចំពោះចម្លើយសាក្សីដែលបានថតសម្លេង និងសក្ខីកម្មនៅពេលសវនាការ"[5]។

៣- បុគ្គលចំនួន១២នាក់ដែលមេធាវីការពារក្តីបានទាមទារ គឺបានផ្តល់សម្ភាសន៍ដោយរំលោភទៅលើវិធានផ្ទៃក្នុង មិនដូចបុគ្គលទាំឡាយដែលជាកម្មវត្ថុនៅក្នុងសំណើកាលពីលើកមុននោះទេ គឺមិនបានកំណត់កាលវិភាគដើម្បីកោះហៅឲ្យមកធ្វើជាសាក្សីនៅក្នុងសវនាការនោះឡើយ។ ជាងនេះទៅទៀត សក្ខីកម្មដែលបានស្បថរបស់គេផ្តល់ជូន កសចស ត្រូវបានសហព្រះរាជអាជ្ញាដាក់ជូន ដើម្បីពិចារណាអំពីតម្លៃភ័ស្តុតាងផ្ទាល់របស់គេ ក្នុងករណីមិនមានសក្ខីកម្មរបស់គេទាំងនោះនៅពេលសវនាការ[6]។ កំណត់

[3] ឯកសារលេខ E241 សំណើរបស់ អៀង សារី ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការជាសាធារណៈ និងទទួលយកភស្តុតាងពាក់ព័ន្ធនឹងទម្លាប់អនុវត្តន៍ជាទូទៅនិងជាលក្ខណៈប្រព័ន្ធនៃការស្តាប់ចម្លើយ ដោយពុំមានការថតសំឡេង ឬរូបភាព, ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (តទៅនេះហៅថា "សំណើ") បានទទួលដំណឹងនៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[4] ឯកសារលេខ E241 សំណើ ត្រង់ទំព័រ ១ និងជើងទំព័រ ៣ (ភាសាអង់គ្លេស) (ដោយដកស្រង់នូវខ្សែអាត់សំឡេងនៃការស្តាប់យកចម្លើយចំនួន ៩ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយចំនួន ៣)។

[5] ឯកសារលេខ E241 សំណើ ត្រង់ទំព័រ ៧ (ភាសាអង់គ្លេស)។

[6] ឯកសារលេខ E241 សំណើ ត្រង់កថាខណ្ឌ ១។

ហេតុទាំងនេះជាប្រភេទភ័ស្តុតាងបន្ថែម និងមិនមែនដាក់ដើម្បីបង្ហាញអំពើ និងសកម្មភាពរបស់ជនជាប់ចោទទេ ដូចដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ[7]។

៤- អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួននឹងពិចារណាកំណត់ហេតុដែល កសចស បានធ្វើ “ស្របតាមគោលការណ៍ច្បាប់ដូចដែលបានកំណត់នៅក្នុងសេចក្តីសម្រេច E96/7”[8]។ ការណ៍នេះចាំបាច់ត្រូវបញ្ចូលនូវការទទួលស្គាល់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសេចក្តីសម្រេចនេះ ថាការថតសម្លេងនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស សន្មតពីភាពគួរឲ្យជឿទុកចិត្តបាន និងភាពជាប់ទាក់ទង[9]។ ឯកសារទាំងនេះនឹងត្រូវបានដាក់ឲ្យធ្វើការ“ជំទាស់”[10] និងជំទាស់តាមរយៈការដាក់សំណើជាលាយលក្សណ៍អក្សរផងដែរ[11] ដែលផ្តល់ឲ្យមេធាវីមានឱកាសគ្រប់គ្រាន់ ក្នុងការលើកការទាមទារណាមួយដែលមេធាវីអាចធ្វើ ពាក់ព័ន្ធនឹងទម្ងន់ដែលបណ្តាលមកពីកំណត់ហេតុស្តាប់ចម្លើយនោះ។

៥- ដើម្បីគាំទ្រដល់ការដាក់សេចក្តីសន្និដ្ឋានមួយក្នុងចំណោមសេចក្តីសន្និដ្ឋាននានាពីមុនរបស់មេធាវីការពារក្តី អៀង សារី មេធាវីការពារក្តី ខៀវ សំផន ក៏បានចោទប្រកាន់ផងដែរអំពីភាពមិនសមស្របនីតិវិធីក្នុង

---

[7] សូមមើល ឯកសារលេខ **E223/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន ស្នើសុំកែសម្រួលបញ្ជីភស្តុតាងជាក់លាក់, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១២, កថាខណ្ឌ ១២, ដោយដកស្រង់ចេញពី ឯកសារលេខ **E96/8** សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី ១-១៦, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២, កថាខណ្ឌ ១៧។

[8] ឯកសារលេខ **E223/2** សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុសាសន៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223), ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២, កថាខណ្ឌ ៩ (តទៅនេះហៅថា “អនុស្សរណៈស្តីពីសវនាការដេញដោលលើឯកសារនាពេលខាងមុខ”)។

[9] ឯកសារលេខ **E96/7** សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២, កថាខណ្ឌ ២៦។

[10] ឯកសារលេខ **E223/2** អនុស្សរណៈស្តីពីសវនាការដេញដោលលើឯកសារនាពេលខាងមុខ ត្រង់កថាខណ្ឌ ៩។

[11] ឯកសារលេខ **E223/2** អនុស្សរណៈស្តីពីសវនាការដេញដោលលើឯកសារនាពេលខាងមុខ ត្រង់កថាខណ្ឌ ១៤។

កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស[12]។ ក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួនបានដោះស្រាយរួចហើយនូវកង្វល់ដែលពាក់ព័ន្ធនឹងវិការៈដែលបានចោទប្រកាន់ ក្នុងការធ្វើសម្ភាសន៍សាក្សីដោយអ្នកស៊ើបអង្កេតរបស់ កសចស និងបានបង្ហាញថា សេចក្តីសម្រេចបន្ថែមមួយទៀត នឹងចេញក្នុងពេលដ៏ខ្លីខាងមុខនេះ“ ដើម្បីឆ្លើយតបទៅនឹងសំណើមួយចំនួនស្រដៀងគ្នានេះ[13]”។

៦- ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយរួចហើយនូវកង្វល់ជាច្រើនដែលមេធាវីលើកឡើងនៅទីនេះ អង្គជំនុំជម្រះបានសម្រេចថា “មិនចាំបាច់ថតសម្លេង ឬវីដេអូ ក្នុងការធ្វើសម្ភាសន៍ជាមួយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ឡើយ”[14]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា៖

> *នៅពេលមានការអះអាងថាមានការបំប្លែងកំណត់ហេតុនៃការស្តាប់ចម្លើយ ដើម្បីបំប្លែងខ្លឹមសារនៃចម្លើយសាក្សីដោយចេតនា និងដោយដឹងច្បាស់ និងធ្វើឲ្យរាំងស្ទះដល់កិច្ចស៊ើបសួរ។ ភាគីគប្បីដាក់សំណើទៅអង្គបុរេជំនុំជម្រះ ឲ្យធ្វើមោឃភាព កំណត់ហេតុស្តាប់ចម្លើយ ឬកិច្ចស៊ើបសួរទាំងមូល អនុលោមតាមវិធាន៧៦។ បន្ទាប់មកថា ក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនពិចារណាបញ្ហាដែលគួរត្រូវបានដោះស្រាយក្នុងអំឡុងពេលស៊ើបសួរឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើយ៉ាងនេះតែក្នុងករណីដែលភាគីអាចបង្ហាញថា*

[12] មតិគាំទ្រសំណើរបស់លោក អៀង សារី E221និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឲ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោលជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ថ្ងៃទី២៩ ខែសីហា ២០១២។

[13] ឯកសារលេខ **E223/2** អនុស្សរណៈស្តីពីសវនាការដេញដោលលើឯកសារនាពេលខាងមុខ ត្រង់កថាខណ្ឌ៩។

[14] ឯកសារលេខ **E142/3** សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេង នៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២, កថាខណ្ឌ ៦។

*ភាគីមិនមានឱកាសរកឃើញនូវការបំប្លែង ដែលត្រូវបានចោទប្រកាន់ នៅមុនពេលបើកសវនាការ ឬក្នុងករណីចាំបាច់ដើម្បីការពារភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី*[15] ។ សេចក្តីសម្រេចនេះពាក់ព័ន្ធនឹងបញ្ហាស្នូលដែលមេធាវីការពារក្តីនៅពេលនេះ កំពុងស្វែងរកប្តឹងឡើងវិញ ដោយមិនបានបង្ហាញបន្ទុកដើម្បីធ្វើយុត្តិកម្មការបើកកិច្ចស៊ើបសួរជាក់លាក់មួយណាទេ ធ្វើដូចនេះគឺផ្ទុយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។

៧- កាលពីមុន អង្គជំនុំជម្រះសាលាដំបូងក៏ធ្លាប់បានបដិសេធផងដែរសំណើមួយរបស់មេធាវីការពារក្តី ដែលសុំឲ្យបើកធ្វើសវនាការទ្រង់ទ្រាយធំមួយស្តីពីការស៊ើបសួរតាមផ្លូវតុលាការដោយឈរលើមូលដ្ឋានការចោទប្រកាន់ទូទៅអំពីភាពលម្អៀងក្នុងការស៊ើបអង្កេត[16]។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ថា "សេចក្តីសម្រេចដែលរងការប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ គឺដីកាដំណោះស្រាយលុបលាងវិការៈនីតិវិធីណាមួយនៅក្នុងកិច្ចស៊ើបសួរ ហើយគ្មានបញ្ហាដែលទាក់ទងទៅនឹងវិការៈនីតិវិធីបែបនេះណាមួយ អាចត្រូវបានលើកឡើង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ"[17]។

៨- សំណើរបស់មេធាវីការពារក្តីសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបើកធ្វើការស៊ើបអង្កេតមួយអនុលោមតាមវិធាន៩៣នៃវិធានផ្ទៃក្នុង យោងទៅដល់សំណើនានាដែលបានធ្វើពីមុនៗមក។ ដូចដែលសហព្រះរាជអាជ្ញាបានឆ្លើយតបរួចមកហើយទៅនឹងសំណើទាំងនោះ សហព្រះរាជអាជ្ញាសូមបញ្ជូនទៅអង្គជំនុំជម្រះ

[15] ឯកសារលេខ **E142/3** សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនិងជាសំឡេង នៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២, កថាខណ្ឌ ៧។

[16] ឯកសារលេខ **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១, ដោយដកស្រង់ចេញពី ឯកសារលេខ E71 ញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១។

[17] ឯកសារលេខ **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ២ (ភាសាអង់គ្លេស)។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជូនបញ្ហានោះទៅអង្គភាពគាំពារការការពារក្តី "អនុលោមតាមអំណាចរបស់ខ្លួន ក្នុងការចេញសោហ៊ុយមួយផ្នែកសម្រាប់ការងារដែលបានអះអាងថាបានធ្វើ នៅពេលដែលការងារនោះធ្វើឡើង ដោយ "មិនចាំបាច់ និងមិនសមហេតុផល""។ សូមមើល *ដូចខាងលើ*, ទំព័រ៣ (ភាសាអង់គ្លេស)។

សាលាដំបូង នូវសេចក្តីសន្និដ្ឋានពាក់ព័ន្ធពីមុនៗ និងដោះស្រាយនៅក្នុងចម្លើយតបនេះតែនៅពេលណាមានការទាមទារថ្មីដាក់នៅក្នុងសំណើ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា មេធាវីការពារក្តីខកខានមិនបានដាក់បន្ទុកចាំបាច់សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងប្រើអំណាចឆន្ទានុសិទ្ធិដើម្បីបើកការស៊ើបសួរ។ ត្រឹមកម្រិតណាមួយដែលមេធាវីការពារក្តីយកបញ្ហានេះភ្ជាប់ជាមួយនឹងនីតិវិធីដែលបានធ្វើហើយដោយសហចៅក្រមស៊ើអង្កេត នោះសហព្រះរាជអាជ្ញាសន្និដ្ឋានថា ១-មេធាវីការពារក្តីបានទទួលដំណឹងអំពីការអនុវត្តរបស់សហចៅក្រមស៊ើបអង្កេតតាមរយៈការស៊ើបអង្កេតតាមផ្លូវតុលាការ ហើយមេធាវីខ្លួនឯងខកខានមិនបានលើកការកង្វល់នេះភ្ជាប់ទៅនឹងការអនុវត្តនៅដំណាក់កាលពាក់ព័ន្ធ ២-មេធាវីការពារក្តីខកខានមិនបានបង្ហាញថា ភាពមិនប្រក្រតីណាមួយកើតឡើងនៅក្នុងអំឡុងពេលស៊ើបសួរដែលអាចធានាការស៊ើបអង្កេតនៅដំណាក់កាលជំនុំជម្រះទេ និង៣-ប្រសិនបើមេធាវីការពារក្តីចង់ធ្វើសេចក្តីសន្និដ្ឋានអំពីតម្លៃភស្តុតាងដែល កសចស បានប្រមូល នោះមេធាវីការពារក្តីអាចប្រើប្រាស់ឲ្យអស់នីតិវិធីដែលនៅមានធរមានដាក់ដោយអង្គជំនុំជម្រះ។

## II. **អំណះអំណាង**

៩- ជាដំណោះស្រាយ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង "**បើកសវនាការជាសាធារណៈមួយ** ដើម្បីធ្វើការស៊ើបអង្កេតលើការអនុវត្តរបស់ កសចស ក្នុងការធ្វើសម្ភាសន៍សាក្សីមួយចំនួនដោយមិនបានថតសម្លេង និងអានុភាពអាចមានចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានថតសម្លេង និងសក្ខីកម្មនៅពេលសវនាការ[18]។ មេធាវីការពារក្តីបានធ្វើសំណើនេះ "ដោយស្របទៅតាមវិធាន៩៣ និង២១"[19]។ វិធាន៩៣អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង ចេញដីកាបង្គាប់ឲ្យបើកកិច្ចស៊ើបសួរបន្ថែម "បើសិនជា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ចាំបាច់ត្រូវបើកកិច្ចស៊ើបសួរថ្មីមួយទៀត"[20]។ វិធាន២១ចែងអំពី "គោលការណ៍ជាមូលដ្ឋាន" មួយចំនួនដែលគ្រប់គ្រងនីតិវិធីចំពោះមុខ អវតក[21]។ មេធាវីការពារក្តីតវ៉ាថា ការអនុញ្ញាតលើសំណើរបស់ពួកគេ អាច "ធានាឲ្យមានតម្លាភាព" និងការពារផលប្រយោជន៍របស់ អៀងសារី ដូចដែលបានតម្រូវ ដោយវិធាន២១នៃវិធានផ្ទៃក្នុង[22]។

[18] ឯកសារលេខ **E241** សំណើ ត្រង់ទំព័រ ៧។

[19] ឯកសារលេខ **E241** សំណើ ត្រង់ទំព័រ ១។

[20] វិធាន ៩៣(១)។

[21] វិធាន ២១។

[22] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ១១(ច)។

សហព្រះរាជអាជ្ញានឹងបង្ហាញខាងក្រោមថា មេធាវីការពារក្តីបានខកខានជាថ្មីម្តងទៀត ក្នុងការបង្ហាញឲ្យឃើញ អំពីភាពមិនត្រឹមត្រូវមួយចំនួនទាក់ទងនឹងនីតិវិធី ដែលសក្តិសមនឹងទទួលបាននូវដំណោះស្រាយ។

## ក. ការចោទថាមានវិការៈនីតិវិធីដោយការមិនគោរពតាមវិធានបញ្ញត្តិក្នុងការស៊ើបសួរត្រូវបានលុបលាងដោយដីកាដំណោះស្រាយ

១០- សំណើនេះផ្អែកលើមូលដ្ឋាននៃវិការៈនីតិវិធីដែលបានចោទប្រកាន់នៅក្នុងកិច្ចស៊ើបសួររបស់តុលាការ - ជាពិសេស វិធីដែលក្នុងនោះការធ្វើសម្ភាសន៍បុគ្គលចំនួន១២នាក់ត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ កសចស[23]។ ក៏ប៉ុន្តែ ដូចដែលបានសម្រេចដោយអង្គជំនុំជម្រះកាលពីលើកមុនរួចហើយ "វិធានផ្ទៃក្នុងមិនបានកំណត់ឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិនិត្យអំពីភាពត្រឹមត្រូវទាក់ទងនឹងនីតិវិធាននៃកិច្ចស៊ើបសួរ បន្ទាប់ពីខ្លួនបានទទួលសំណុំរឿងនេះ"[24]។

១១- អនុលោមតាមក្របខណ្ឌនីតិវិធីរបស់ អវតក ការស្នើសុំទាក់ទងអំពីវិការៈនីតិវិធី អាចត្រូវបានលើកឡើងតែក្នុងអម្លុងដំណាក់កាលមុនសវនាការតែប៉ុណ្ណោះ។ ដូចដែលអង្គជំនុំជម្រះនេះបានរកឃើញ " នៅក្នុងក្របខណ្ឌច្បាប់របស់ អវតក ដែលទាក់ទងនឹងកិច្ចស៊ើបសួរ មាននីតិវិធីការពារគ្រប់គ្រាន់សម្រាប់ជនជាប់ចោទ រួមទាំងឱកាសដើម្បីលើកជូនសហចៅក្រមស៊ើបអង្កេតស្តីពីបញ្ហាណាមួយ និងបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះប្រឆាំងនឹងការសម្រេចដែលបានធ្វើឡើងដោយ សចស បើសិនជាយល់ឃើញថាជាការចាំបាច់"[25]។

១២- ការណ៍នេះការពារ រួមទាំង សិទ្ធិក្នុងការធ្វើសំណើសុំឲ្យធ្វើការស៊ើបអង្កេត នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ ព្រមទាំងសំណើសុំនានា "សំណើបែបដូចនេះ នៅពេលដែលគេពិចារណាថាមានប្រយោជន៍ចំពោះការស៊ើបអង្កេត" អនុលោមតាមវិធាន៥៥(១០)។ ដោយអនុលោមតាមវិធាន៧៦ មេធាវីការ

[23] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ២។

[24] ឯកសារលេខ **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92), ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ១៧ (តទៅនេះហៅថា "សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ")។

[25] ឯកសារលេខ **E116** សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ត្រង់កថាខណ្ឌ ១៨។

ពារក្តីមានសិទ្ធិផងដែរក្នុងការស្នើសុំមោឃភាពកំណត់ហេតុស្តាប់ចម្លើយ និងកិច្ចស៊ើបសួរផ្សេងៗទៀត និងប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចបដិសេធណាមួយ[26]។ មេធាវីការពារក្តីខកខានមិនបានប្រើប្រាស់ឱកាសឲ្យអស់នៅក្នុងដំណាក់កាលស៊ើបសួរ ទោះបីជាមានការជូនដំណឹងគ្រប់គ្រាន់អំពីកិច្ចស៊ើបអង្កេតរបស់ កសចស។ ក្នុងករណីនេះ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ក្នុងដំណាក់កាលស៊ើបសួរ ភាគីទាំងអស់មានឱកាសស្មើគ្នាក្នុងការពិនិត្យកំណត់ហេតុស្តាប់ចម្លើយសាក្សី និងភ័ស្តុតាងផ្សេងៗទៀតដែល កសចស ប្រមូលបាន។

១៣- នៅពេលជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ភាគីមានឱកាសបន្ថែមទៀតដើម្បីស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម ហើយប្តឹងឧទ្ធរណ៍ចំពោះការបដិសេធចំពោះសំណើបែបនេះផងដែរ[27]។ មេធាវីការពារក្តី ជាថ្មីម្តងទៀត មិនបានស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមណាមួយ នៅត្រង់ចំណុចនេះ ទាក់ទងនឹងបញ្ហានេះដែលមេធាវីការពារក្តីកំពុងលើកឡើងនៅពេលនេះឡើយ។

១៤- បន្ទាប់ពីឱកាសទាំងអស់នេះដើម្បីដោះស្រាយចំពោះការព្រួយបារម្ភណាមួយដែលគេយល់ឃើញ បានកន្លងផុតទៅដោយសារមេធាវីមិនបានប្រើប្រាស់ ដីកាដំណោះស្រាយត្រូវបានចេញ។ វិធាន៧៦(៧)នៃវិធានផ្ទៃក្នុងបានចែងថា៖ "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវតែលុបលាងវិការៈនីតិវិធីក្នុងពេលស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលទាក់ទងនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកឡើង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ"[28]។ ហេតុដូចនេះ វិធានផ្ទៃក្នុងរបស់ អវតក មានលក្ខណៈច្បាស់លាស់ណាស់ថាការជំទាស់ណាមួយទាក់ទងនឹងនីតិវិធីក្នុងកិច្ចស៊ើបសួរ គឺត្រូវបានកម្រិតត្រឹមដំណាក់កាលមុនការជំនុំជម្រះក្តី។

---

[26] *សូមមើល ផងដែរ* ឯកសារលេខ **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ២ (ភាសាអង់គ្លេស) ("ភាគីទាំងអស់មានលទ្ធភាពដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុ អំពីមោឃភាពផ្នែកណាមួយនៃដំណើរការនីតិវិធី ដែលពួកគេចាត់ទុកជាមោឃៈនៅក្នុងដំណើរការបំពេញកិច្ចស៊ើបសួរ ហើយថាសេចក្តីសម្រេចមួយលើពាក្យសុំនេះ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធានផ្ទៃក្នុង")។

[27] វិធាន ៦៦ នៃវិធានផ្ទៃក្នុង។

[28] *សូមមើល ផងដែរ* ឯកសារលេខ **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ២ (ភាសាអង់គ្លេស)។

១៥- មេធាវីការពារក្តីបានលើកឡើងថា ពីព្រោះខ្លួនមិនបានស្វែងរកធ្វើមោឃភាពកិច្ចស៊ើបសួរឡើយ។ ក៏ប៉ុន្តែ អំណះអំណាងដែលស្វែងរកនៅកិច្ចស៊ើបសួរ ត្រូវបានហាមឃាត់ដោយវិធាន៧៦(៧) នៃវិធានផ្ទៃក្នុង" (គឺថាអំណះអំណាងនេះគ្មានខ្លឹមសារទេ"[29]។ មេធាវីការពារក្តីបានបកស្រាយវិធាន៧៦(៧) ខុស។ គំនិតនៃវិធាននេះ គឺដើម្បីលុបលាងកំហុសនីតិវិធីទាំងអស់ក្នុងកិច្ចស៊ើបសួរ ទោះបីជាថាតើដំណោះស្រាយដែលបានស្វែងរកឈរលើមូលដ្ឋានវិការៈនីតិវិធីដែលបានចោទប្រកាន់ក៏ដោយ ក៏គេគិតថាជាការស្នើសុំមោឃភាព និងសុំស៊ើបសួរបន្ថែម។ ដូចនេះ មិនគិតពីថាតើកិច្ចស៊ើបសួរដែលបានស្វែងរក "ត្រូវបានហាមឃាត់ដោយវិធាន៧៦(៧)ទេ"។ ជំហរផ្នែកច្បាប់ គឺថាវិការៈនីតិវិធីដែលបានចោទប្រកាន់ដែលមេធាវីការពារក្តីកំពុងប៉ុនប៉ងលើកឡើង ត្រូវបានលុបលាងហើយ ហើយមិនអាចគាំទ្រសំណើសុំដំណោះស្រាយនេះបានឡើយ។

១៦- ជាងនេះទៀត សំណើសុំវិធានការណ៍របស់មេធាវីការពារក្តី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបើកធ្វើការស៊ើបអង្កេតចំពោះការអនុវត្តរបស់ កសចស ដោយមិនមានភស្តុតាងបន្តិចបន្តួចសោះ អំពីការជ្រៀតជ្រែកសំខាន់ជាក់ស្តែងលើភស្តុតាងជាសាក្សីនោះ នឹងទៅជាការរំលោភទៅលើការបែងចែកដែលបានកំណត់ជាស្រេចនៅក្នុងវិធានផ្ទៃក្នុង រវាងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះក្តី។ អង្គជំនុំជម្រះសាលាដំបូងមិនមែនជា "ស្ថាប័នសម្រាប់បណ្តឹងឧទ្ធរណ៍ឬពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងសេចក្តីសម្រេចរបស់ [អង្គបុរេ]ជំនុំជម្រះនោះឡើយ"[30]។ ហេតុដូចនេះ "ក្នុងនាមជាបញ្ហាទូទៅ ការជំទាស់ដែលទាក់ទងអំពីដំណាក់កាលនៃនីតិវិធី ឬសេចក្តីសម្រេចដែលបានធ្វើឡើងដោយ សចស និងអង្គបុរេជំនុំជម្រះ នៅក្នុងដំណាក់កាលនៃកិច្ចស៊ើសួរតែងតែលើកស្នើទៅស្ថាប័នមានសមត្ថកិច្ចរបស់តុលាការនៅមុនពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរ"[31]។

១៧- ដូចដែលបានធ្វើការកត់សម្គាល់នៅក្នុង សេចក្តីផ្តើម និងប្រវត្តិនីតិវិធីខាងលើ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ករណីលើកលែងមិនអនុវត្តវិធាន ៧៦(៧)អាចមាន "ប្រសិនជាភាគីនានាអាចបង្ហាញភស្តុតាងឱ្យឃើញថាខ្លួនមិនមានឱកាសរាវរកបញ្ហាដែលបានចោទប្រកាន់ នៅមុនពេលសវនាការជំនុំជម្រះក្តីត្រូវបានបើកធ្វើ ឬបើសិនជាឃើញហាក់ដូចជាមានការចាំបាច់ត្រូវរក្សាការពារភាពត្រឹមត្រូវ

[29] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ១៥។

[30] ឯកសារលេខ **E116** សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ត្រង់កថាខណ្ឌ ១៨។

[31] ឯកសារលេខ **E116** សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ត្រង់កថាខណ្ឌ ១៥។

នៃដំណើរការនីតិវិធី"[32]។ ក្នុងចំណោមករណីលើកលែងទាំងនោះ មិនមានករណីលើកលែងណាមួយត្រូវបានយកមកអនុវត្តនៅទីនេះនោះឡើយ។ មេធាវីការពារក្តីមានឱកាសគ្រប់គ្រាន់ក្នុងការរាវរកបញ្ហាទាំងឡាយដែលខ្លួនបានលើកឡើងនៅក្នុងសំណើសុំរបស់ខ្លួន ដែលក្នុងនេះខ្លួនបានលើកឡើងអះអាងថាពួកគេត្រូវបានប្រាប់ឱ្យដឹងដោយការពិនិត្យមើលឡើងវិញនូវចម្លើយសាក្សី និងការថតសម្លេងនៃការធ្វើសម្ភាសន៍[33]។ ដូចដែលអង្គជំនុំជម្រះនេះបានធ្វើការកត់សម្គាល់កាលពីមុនហើយថា៖

> *ទាំងខ្សែអាត់ថតសម្លេង និងកំណត់ត្រាស្តាប់ចម្លើយ ទាំងអស់នេះសុទ្ធតែ ត្រូវបាន...ដាក់ចូលនៅក្នុងសំណុំរឿងជាបន្តបន្ទាប់ក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរហេតុដូច្នេះភាគីអាចមានលទ្ធភាពពិនិត្យមើលឯកសារទាំងនោះបាន(ទាំងអ្នកចេះភាសាខ្មែរភាសាអង់គ្លេស និងភាសាបារាំង)ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ[34]។*

១៨- ហេតុដូចនេះ អង្គជំនុំជម្រះបានបដិសេធលើសំណើដែលអនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុងដែលធ្វើឡើងដោយមេធាវីការពារក្តីរបស់ នួន ជា ដោយផ្អែកលើភាពមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់ថតសម្លេងហើយនិងកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ កសចស ដោយរកឃើញថា៖ "នៅក្នុងអំឡុងពេលនៃតំណាក់កាលកិច្ចស៊ើបសួរ គ្រប់ភាគីទាំងអស់មានសិទ្ធិអាចចូលទៅពិនិត្យមើលសំណុំរឿងបានដែលក្នុងនោះរួមទាំងខ្សែអាត់ថតសម្លេងផង" ហើយមេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញថា "នៅមុនពេលបើកសវនាការ ជំនុំជម្រះក្តី"មិនមានលទ្ធភាពអាចធ្វើការវាយតម្លៃអំពីអត្ថិភាពនៃភាពមិន ស៊ីសង្វាក់គ្នានៃកំណត់ហេតុជាលាយលក្សណ៍អក្សរបានទេ[35]។ ស្រដៀងគ្នានេះដែរ នៅទីនេះ ការអនុវត្តន៍នូវកតព្វកិច្ចស្តីពីការយកចិត្តទុកដាក់របស់គេ មេធាវីការពារក្តីគួរតែបានធ្វើការពិនិត្យមើលឡើងវិញរួចហើយនូវខ្សែអាត់ថតសម្លេង និងកំណត់ហេតុជាលាយលក្សណ៍អក្សរនៃការធ្វើសម្ភាសន៍ទាំងនេះតាំងពីមុននេះ។ មិនមានការអនុគ្រោះបែបនេះ ចំពោះការខកខានមិនបានរកឃើញ និងលើកឡើង

[32] ឯកសារលេខ **E142/3** សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២, កថាខណ្ឌ ៧ (តទៅនេះហៅថា "សេចក្តីសម្រេចលើការស្តាប់ចម្លើយសាក្សី")។

[33] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ២ និង ជើងទំព័រ ៣។

[34] ឯកសារលេខ **E142/3** សេចក្តីសម្រេចលើការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌ ៦, ៨។

[35] ឯកសារលេខ **E142/3** សេចក្តីសម្រេចលើការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌ ៨។

នូវសេចក្តីព្រួយបារម្ភដោយស្មានៗថា ឥឡូវនេះ មេធាវីការពារក្តីកំពុងតែលើកឡើងនូវនៅមុនពេលបើកសវនាការនោះទេ។

១៩- លោកស្រីចៅក្រម Cartwright ក្នុងពេលថ្មីៗនេះ បានធ្វើការបញ្ជាក់អះអាងសារជាថ្មីអំពីគោលការណ៍ទាំងនេះដល់ភាគីនានានៅក្នុងតុលាការថា៖

*ហេតុដូច្នេះជាវិធានទូទៅនោះគឺថាមានសច្ចធារណ៍គតិយុត្តិ និយាយអំពីសុច្ចរិតភាពនៃការស៊ើបអង្កេត ដែលថា រាល់ការពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ឬក៏កម្មវត្ថុណាមួយ ដែលកើតមានឡើងក្នុងអំឡុងពេលស៊ើបអង្កេតនេះ ត្រូវតែលើកឡើងក្នុងអំឡុងពេលស៊ើបអង្កេតនោះតែម្តង។ ហើយឥឡូវនេះគឺនៅក្នុងពេលសវនាការនេះ ការស៊ើបអង្កេតត្រូវបានចាត់ទុកថាជាចំណុចចាប់ផ្តើម ហើយអាចជំទាស់តវ៉ាតែនៅក្នុងករណីលើកលែងមួយចំនួនតែប៉ុណ្ណោះ។*

*រាល់ការជំទាស់តវ៉ាទាំងនោះ ត្រូវតែកុំមានពាក់ព័ន្ធជាមួយនឹងបញ្ហាបច្ចេកទេស ក៏ប៉ុន្តែវាត្រូវតែពាក់ព័ន្ធទៅនឹងខ្លឹមសារតែប៉ុណ្ណោះ។ ហើយការលើកឡើងចំពោះករណីលើកលែងនេះ ភាគីត្រូវឆ្លើយតបលក្ខខណ្ឌរបស់អង្គជំនុំជំម្រះដែល ភាគីមួយមានកង្វល់ដែលមូលដ្ឋានច្បាស់លាស់ អំពីភាពគួរឲ្យជឿជាក់បាននៅត្រង់ផ្នែកណាមួយនៃការស៊ើបអង្កេត។ ដូច្នេះយើងមិនអាចយកពាក្យពេចន៍នៃច្បាប់ខំមិនឲ្យ ដែលមិនអនុញ្ញាត្តិអោយលើកបញ្ហាណាមួយដោយគ្មានមូលដ្ឋអំណះអំណាងច្បាស់លាស់នោះទេ។*

*...[ភាគី]ចាំបាច់គោងតែបំពេញលក្ខខណ្ឌសព្វគ្រប់ជូនអង្គជំនុំជម្រះសាលាដំបូងថាមានហេតុផលដែលមានមូលដ្ឋានត្រឹមត្រូវ ដើម្បីវិលត្រឡប់មកក្នុងកិច្ចស៊ើបសួរវិញ ហើយធ្វើការស៊ើបអង្កេត*[36]*។*

---

[36] ឯកសារលេខ **E1/123.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី , ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២, ទំព័រ ៤៣ (ភាសាអង់គ្លេស); សូមមើលផងដែរ *ដូចខាងលើ* ត្រង់ទំព័រ ៣៦-៣៧ (ភាសាអង់គ្លេស) (នៅពេលចៅក្រម Lavergne បានកត់សម្គាល់ "ចំណុចជាក់ស្តែងមួយចំនួន" ដោយរួមមាន "កិច្ចស៊ើបសួរដែលបានធ្វើឡើងមុនការជំនុំជម្រះនេះ គឺថាមានរយៈពេលរាប់ឆ្នាំមកហើយ។ ហើយនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ កិច្ចស៊ើបសួរត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង។ ក្រុមមេធាវីការពារក្តី និងជនជាប់

២០- តាមពិត ដូចដែលចៅក្រម Cartwright បានយល់ឃើញដូច្នោះដែរ ការប្រព្រឹត្តិរបស់ កសចស គឺត្រូវបានគេគិតថាជា សច្ចធារណ៍នៃប្រក្រតីភាព ដែលមិនអាចត្រូវបានជំទាស់ដោយញត្តិនានាដែល "មានអំណះអំណាងគ្រាន់តែជាការស្មានៗមិនប្រាកដប្រជា ឬមិនមានខ្លឹមសារអ្វីសោះឡើយ" ដូចជា សំណើមួយនេះជាដើម[37]។

## ខ. មេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញថាការទង្វើដែលត្រូវបានចោទប្រកាន់ បំពានលើវិធានផ្ទៃក្នុង

២១- ទោះបីជាដីកាដំណោះស្រាយមិនបានលុបលាងលើកំហុសនីតិវិធីទាំងអស់ក៏ដោយ ក៏សំណើនេះគួរត្រូវគេបដិសេធចោលដោយមូលហេតុថាមេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញថា ការអនុវត្តន៍សកម្មភាពស៊ើបអង្កេតរបស់ កសចស បានបំពានលើ វិធានផ្ទៃក្នុងនោះឡើយ។ មូលដ្ឋានជាសារវន្តនៅក្នុងអំណះ អំណាងរបស់មេធាវីការពារក្តី គឺថាប្រសិនបើអ្នកស៊ើបអង្កេតបាននិយាយទៅកាន់សាក្សីដោយគ្មានការ ថតសម្លេង ឬ ការកត់ត្រា ពីអន្តរសកម្មភាពទាំងនោះទេ គឺអាចសន្និដ្ឋានថាពួកគេបានបំពានលើវិធានផ្ទៃក្នុងហើយ។ សេចក្តីសន្និដ្ឋានស្នើសុំនេះ គឺផ្ទុយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនៅលើបញ្ហានេះ។ មេធាវីការពារក្តីបានស្វះស្វែងធ្វើការតវ៉ាឡើងវិញក្តីលើចំណុចនេះ តាមរយៈការដាក់ជូននូវការបកស្រាយបែបប្រឌិតដែលមានលក្ខណៈផ្ទុយនឹងអត្ថបទ និងខ្លឹមសារនៃវិធាននេះ។ សហព្រះរាជអាជ្ញា នឹងបង្ហាញបញ្ហានេះតាមរយៈការបកស្រាយពន្យល់លើអំណះអំណាងរបស់មេធាវីការពារក្តីម្តងមួយៗតាមលំដាប់លំដោយដែលគេបានលើកឡើង។

២២- ដំបូង មេធាវីការពារក្តីងាកទៅរកវិធាន៥៥.៧ ដោយបានថ្លែងថា "វិធាន៥៥.៧ ដែលចែងពី "បទប្បញ្ញត្តិទូទៅទាក់ទងទៅនឹងការស៊ើបសួរ"បានចែងថា "រាល់ការស្តាប់ចម្លើយ ឬសួរ យកចម្លើយទាំងអស់របស់សហចៅក្រមស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ"[38]។ កំណត់ហេតុស្តាប់ចម្លើយត្រូវបានបង្កើតឡើង សម្រាប់ការស្តាប់ចម្លើយនីមួយៗដែលមេធាវីការពារក្តីអះអាងថា វា

ចោទក៏អាចចូលមើលសំណុំរឿងនេះបានដែរ ...។ យើងមិនពិភាក្សាពីកិច្ចស៊ើបសួរនៅពេលនេះទេ ...។ នៅទីនេះ យើងត្រូវសិក្សា និងពិនិត្យទៅលើបញ្ហាសំខាន់ៗជាសារធាតុ។ យើងមិនត្រូវចោទសួរដដែលៗ ពាក់ព័ន្ធនឹងបញ្ហានានាដែលពាក់ព័ន្ធនៃកិច្ចស៊ើបសួរ ")។

[37] ឯកសារលេខ **E142/3** សេចក្តីសម្រេចលើការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌ ១០។

[38] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ៦ (គូសបញ្ជាក់បន្ថែមដោយមេធាវីការពារក្តី)។

មានបញ្ហា[39]។ តាមពិត កំណត់ហេតុទាំងនេះជាកំណត់ហេតុដែល សហព្រះរាជអាជ្ញា បានដាក់ជូន ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណា។ ដូច្នេះ វិធាន៥៥.៧ មិនត្រូវបានបំពាននោះទេ។

២៣- បន្ទាប់មកទៀតមេធាវីការពារក្តី បានប៉ុនប៉ងបង្ហាញឲ្យឃើញថាទង្វើរបស់អ្នកស៊ើបអង្កេត ដែលទទួលរងចោទប្រកាន់នេះ បានបំពានលើវិធាន៦២.៣ និង ៥១.៨ នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្តីបានថ្លែងថា៖

> *វិធាន៦២.៣ តម្រូវឲ្យអ្នកស៊ើបអង្កេតរបស់ កសចស អនុវត្តកិច្ចស៊ើបសួរក្រោមការត្រួតពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត។ វិធាននេះក៏បានចែងផងដែរថា នៅពេលខ្លួនទទួលបានដីកាចាត់ឲ្យស៊ើបសួរជំនួសពីសហចៅក្រមស៊ើបអង្កេត អ្នកស៊ើបអង្កេតរបស់ កសចស ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពី* "ការស៊ើបសួរនិងលទ្ធផលនៃការស៊ើបសួរ" *ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន៥១.៨ តាមករណីសមស្រប*"[40]។

២៤- ជាថ្មីម្តងទៀត វាច្បាស់ណាស់ដែលថា កំណត់ហេតុស្តាប់ចម្លើយត្រូវបានដាក់ជូនសាក្សីទាំងនោះពិនិត្យ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មេធាវីការពារក្តីបានបន្តលើកឡើងថា វិធាន៦២.៣ ត្រូវបានបំពាន ដោយសាររបាយការណ៍ទាំងនោះមិនស្របទៅលក្ខខណ្ឌមានចែងក្នុងវិធាន៥១.៨ ដែលតម្រូវអោយ

---

[39] សូមមើល ឯកសារលេខ **D108/6/10** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៨; ឯកសារលេខ **D125/168** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៨; ឯកសារលេខ **D91/16** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧; ឯកសារលេខ **D369/32** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១០; ឯកសារលេខ **E3/369** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨; ឯកសារលេខ **D125/92** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០៨; ឯកសារលេខ **D232/70** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៩; ឯកសារលេខ **D369/30** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១០; ឯកសារលេខ **D125/26** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០៨; ឯកសារលេខ **D232/46** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩; ឯកសារលេខ **D232/74** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩; ឯកសារលេខ **D232/32** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៩។

[40] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ៧ (គូសបញ្ជាក់បន្ថែមដោយមេធាវីការពារក្តី)។

ដាក់ បញ្ចូលនូវព័ត៌មានស្តីពី “រយៈពេលសម្ភាសន៍ និងរយៈពេលសម្រាកចន្លោះពេលសម្ភាសន៍ណាមួយ”[41]។ ពាក់ព័ន្ធនឹងសាក្សីចំនួន ១២នាក់ ដែលត្រូវបានស្នើឡើងមេធាវីការពារក្តីមិនបានបង្ហាញថាពីរបៀបដែលគេមិនបានអនុវត្តតាមវិធាននេះយ៉ាងម៉េចនោះឡើយ។

២៥- ការអនុវត្តជាបឋមនូវវិធាន៥១(៨)នៃវិធានផ្ទៃក្នុង គឺមានការជាប់ទាក់ទងគ្នាទៅនឹងរបាយការណ៍នានាស្តីពីការចាប់ខ្លួនដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា ហើយនៅក្នុងបរិបទនេះ ការអនុវត្តបញ្ញត្តិទាំងអស់នៃវិធាននេះត្រូវតែធ្វើជាចាំបាច់ដោយខានមិនបាន។ សហព្រះរាជអាជ្ញាមិនមានឆន្ទានុសិទ្ធិដើម្បីកំណត់ថាតើព័ត៌មានអ្វីខ្លះដែលត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍ស្តីពីការចាប់ខ្លួននោះឡើយ ប៉ុន្តែ “ត្រូវដាក់បញ្ចូល”គ្រប់ព័ត៌មានទាំងអស់ដែលបានចែងកំណត់នៅក្នុងកថាខណ្ឌចាប់ពី(ក) ដល់(ញ)។ វិធាន៦២(៣)បានអនុញ្ញាតឲ្យយ៉ាងច្បាស់លាស់នូវឆន្ទានុសិទ្ធិទៅឲ្យ កសចស ស្តីអំពីថាតើបទប្បញ្ញត្តិណាខ្លះនៃវិធាន៥១(៨) ដែលត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍របស់ខ្លួន ស្តីពីការធ្វើសម្ភាសន៍សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដោយថ្លែងថាបទប្បញ្ញត្តិទាំងឡាយត្រូវតែអនុវត្តតាម “ឲ្យបានត្រឹមត្រូវ” ។

២៦- សន្និទានភាពជាមូលដ្ឋាននៅក្នុងវិធីសាស្ត្ររបស់អ្នកធ្វើសេចក្តីព្រាង លើវិធាន៥១.៨ និងវិធាន៦២.៣ ជាក់ស្តែង។ កាលណាវិធាន៥១.៨ ត្រូវបានអនុវត្តចំពោះសហព្រះរាជអាជ្ញា លើកឡើងអំពីស្ថានភាពមួយដែលនៅក្នុងនោះ ជនណាម្នាក់ត្រូវបានសង្ស័យ ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរណាមួយ ត្រូវបានដកហូតនូវសេរីភាព និងកំពុងត្រូវបានសួរចម្លើយដោយសហព្រះរាជអាជ្ញា ដែលជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីណា នៅចំពោះមុខ អវតក។ នៅក្នុងបរិបទនេះ វាជាការសមស្របក្នុងការធ្វើអាណត្តិស្តីពីការដាក់បញ្ចូលនូវប្រភេទមួយចំនួននៃព័ត៌មានទៅក្នុងរបាយការណ៍ រួមមាន រយៈពេលនៃការសួរចម្លើយណាមួយដល់ជនសង្ស័យ និងរយៈពេលសម្រាកចន្លោះពេលសួរចម្លើយ។ ការពិចារណា ដូចគ្នានេះ មិនអនុវត្តចំពោះការស្តាប់ចម្លើយសាក្សីដែលបានធ្វើឡើងដោយ កសចស ទេ ដែលជាការិយាល័យអព្យាក្រិតមួយរបស់តុលាការដែលតួនាទីរបស់ខ្លួន គឺត្រូវស្វែងរកការពិត និងត្រូវដំណើរការទៅដោយមិនលំអៀង[42]។ នេះគឺជាមូលហេតុនៃវិធាន៦២.៣ ដែលអនុវត្តចំពោះការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី តែប៉ុណ្ណោះ[43] បានបន្សល់ទុកនូវវិសាលភាព និងបែបបទ

---

[41] វិធាន ៥១(៨)(ឆ)។

[42] វិធាន៥៥.៥ នៃវិធានផ្ទៃក្នុង ។

[43] អនុលោមតាមវិធាន៦២.៣.ខ អ្នកស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតឲ្យសួរចម្លើយជនត្រូវចោទឡើយ។

នៃការអនុវត្តវិធាន៥១.៨ នៅក្នុងឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។ ភាពខុសគ្នានេះក៏មានស្តែងឡើង នៅក្នុងវិធាន២៥ផងដែរ ដូចដែលបានពន្យល់បន្ថែមនៅខាងក្រោមដូច្នោះ គឺតម្រូវឲ្យថតសម្លេង ឬឲ្យមានកំណត់ហេតុសួរចម្លើយ កាលណាសួរចម្លើយជនសង្ស័យ ឬជនត្រូវចោទ ក៏ប៉ុន្តែមិនមែនចំពោះសាក្សីនោះទេ។

២៧- ដោយបានប្រឈមនឹងការផ្តល់ឆន្ទានុសិទ្ធិដល់ កសចស និងយ៉ាងណាក៏ដោយ ក្នុងគោលបំណងដើម្បីធ្វើការអះអាងថា វិធានផ្ទៃក្នុងណាមួយត្រូវបានបំពាននោះ មេធាវីការពារក្តីគ្រាន់តែ សរសេរវិធាននោះសាជាថ្មីឡើងវិញ។ ដូច្នេះ បន្ទាប់ពីបានដកស្រង់វិធាន៦២(៣) ថាជា ភាសា "សមស្រប" មេធាវីការពារក្តីបានថ្លែងថា៖ "វិធាន៥១(៨) ដាក់តារាងព័ត៌មាន ដោយអនុលោមតាមវិធាន៦២(៣) ត្រូវដាក់បញ្ចូលក្នុងកំណត់ហេតុរបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស អំពីកិច្ចស៊ើបសួរ និងលទ្ធផលនៃការស៊ើបសួរ"[44]។ មេធាវីការពារក្តីថាអាណត្តិ ជាឆន្ទានុសិទ្ធិ។ យ៉ាងណាក៏ដោយ ដូចដែលបានសរសេរយ៉ាងជាក់ស្តែង វិធានផ្ទៃក្នុងនេះ មិនត្រូវបានបំពានឡើយ។

២៨- បន្ទាប់មក មេធាវីការពារក្តីបង្ហាញថាវិធាន២៥ ត្រូវបានបំពាន។ ឆ្លើយតបទៅនឹងការទាមទារស្រដៀងនេះក្នុងសេចក្តីសន្និដ្ឋានពីមុនៗ[45] សហព្រះរាជអាជ្ញាបានបង្ហាញថា វិធាន២៥.២ ដែលតម្រូវឲ្យការសួរចម្លើយ ត្រូវថតសម្លេង ឬថតរូបភាព គឺអនុវត្តបានតែចំពោះជនសង្ស័យ និងជនត្រូវចោទប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាបានពន្យល់នៅពេលនោះថា៖

> *ក្នុងការព្យាយាមដើម្បីបង្កើតឡើងនូវចំណាប់អារម្មណ៍មួយនៃការប្រព្រឹត្តខុស មេធាវីការពារក្តីមានការភាន់ច្រឡំ ដោយខំស្វែងរកសុំឲ្យយកវិធាន២៥.២ មកប្រើសំរាប់ការធ្វើសម្ភាសន៍សាក្សីរបស់ កសចស ដោយលើកឡើងថា នៅក្នុងកាលៈទេសៈដែលមន្ត្រីអ្នកស៊ើបអង្កេតរបស់ កសចស មិនអាចមានលទ្ធភាពថតជាខ្សែអាត់សម្លេង ឬជាវីដេអូនៃការធ្វើសម្ភាសន៍បាន នោះទាមទារឲ្យអ្នកស៊ើបអង្កេតបញ្ជាក់អំពីមូលហេតុដែលមិនអាចធ្វើ*

[44] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ៨ (គូសបញ្ជាក់បន្ថែម)។

[45] ឯកសារលេខ **E234** សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឲ្យ ក.ស.ច.ស ធ្វើការបញ្ជាក់ ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ឲ្យផ្តល់ភស្តុតាង ទាក់ទងនឹងការស្តាប់ចម្លើយនេះ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១២, កថាខណ្ឌ ១១។

ដូច្នេះបានជាលាយលក្ខណ៍អក្សរ។ អានភ្ជាប់គ្នាជាមួយផ្នែកផ្សេងៗទៀតនៃវិធាន២៥ ដែលក្រុមមេធាវីការពារក្តីមិនបានលើកយោង ឬមិនបានលើកយកមកពិភាក្សា វាច្បាស់ណាស់ថា វិធាន២៥.២ គឺអនុវត្តបានតែធ្វើសម្ភាសន៍ជនសង្ស័យ ឬជនត្រូវចោទតែប៉ុណ្ណោះ។

វិធាន២៥.១ រៀបរាប់អំពីគោលការណ៍ណែនាំសម្រាប់ការថតខ្សែអាត់ថតសម្លេង ឬជាខ្សែវីដេអូដែលត្រូវតែអនុវត្តតាម "ពេលណាដែលអាចធ្វើទៅបាន នៅពេលដែលសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត សួរយកចម្លើយពីជនសង្ស័យ ឬជនត្រូវចោទ"។ វិធាន២៥.២ នៃវិធានផ្ទៃក្នុង បានចែងបន្តពីនោះមកទៀត ដោយបានពន្យល់អំពីនីតិវិធីដែលត្រូវប្រើ នៅពេលដែលការថតខាងលើនេះមិនអាចធ្វើទៅបាន៖ "បុគ្គលម្នាក់អាចត្រូវសួរយកចម្លើយដោយមិនបាច់មានការថតសម្លេង ឬថតជារូបភាព នៅពេលណាដែលកាលៈទេសៈរារាំងចំពោះការថតសម្លេងបែបនេះ។ ក្នុងករណីនេះ មូលហេតុមិនអាចថតសម្លេងបានក្នុងពេលសួរយកចម្លើយ នឹងត្រូវបញ្ជាក់ក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ..."។ បើមានការមន្ទិលសង្ស័យណាមួយថា វិធាន២៥.២ ក៏សំដៅជាពិសេសចំពោះជនសង្ស័យ ឬជនត្រូវចោទ ដែលមិនឈានទៅដល់វិធាន២៥.៤ ដែលបានចែងថា៖ "សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត អាចជ្រើសយកនីតិវិធីដែលមានចែងនៅក្នុងវិធាននេះ នៅពេលធ្វើការសួរយកចម្លើយជនដទៃទៀត ក្រៅពីជនដែលបានរៀបរាប់ខាងលើ..."[46]។ មានតែ "ជន" មួយចំនួនដែលបាន "លើកឡើងខាងលើនេះ" តែប៉ុណ្ណោះ គឺជនសង្ស័យ និងជនត្រូវចោទ។ និយាយតាមវិធីម្យ៉ាងទៀត បើសិនជាការប្រើពាក្យ "ជន" នៅក្នុងវិធាន២៥.២ ដែលមានន័យចង់សំដៅទៅលើជនគ្រប់រូប ជាជាងសំដៅទៅលើជនសង្ស័យ និងជនត្រូវចោទនោះ វិធាន២៥.៤ ត្រូវបកស្រាយលើសពីខ្លឹមសារពិតហើយ ពីព្រោះគ្មាន "ជនណាផ្សេងទៀត" នៅក្នុងវិធាន២៥.៤ ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងការបកស្រាយដោយ ដោយន័យទូទៅចំពោះពាក្យ "ជន" នៅក្នុងវិធាន២៥.៤ នោះឡើយ។ អាស្រ័យហេតុនេះ ការធ្វើសម្ភាសន៍សាក្សីគឺត្រូវបានស្ថិតនៅក្រោមវិធាន២៥.៤ ដែលបញ្ជាក់យ៉ាងច្បាស់ថា កសចស "អាចជ្រើសយក" ការអនុវត្តតាមការកំណត់ដូចនៅក្នុងវិធាន២៥.១-៣ ប៉ុន្តែមិនត្រូវបានបង្ខំឲ្យត្រូវតែធ្វើដូច្នេះឡើយ។ អង្គជំនុំជម្រះសាលា

[46] វិធាន ២៥.៤ (គូសបញ្ជាក់បន្ថែម)។

*ដំបូង ក៏បានធ្វើសេចក្តីសន្និដ្ឋានផងដែរថា វិធានផ្ទៃក្នុងរបស់ អវតក មិនបានតម្រូវថា អ្នកស៊ើបអង្កេតរបស់ កសចស ត្រូវថតបទសម្ភាសន៍សាក្សីដោយប្រើឧបករណ៍ថតសម្លេង/ថតរូបភាព ឬថតរយៈពេលពិតប្រាកដនៃការធ្វើបទសម្ភាសន៍សាក្សី និងរយៈពេលសម្រាកនៅក្នុងចន្លោះពេលនៃការធ្វើសម្ភាសន៍នោះទេ*[47]។

២៩- នៅក្នុងសំណើនោះ មេធាវីការពារក្តីបានអះអាងថា សហព្រះរាជអាជ្ញា (និងជាពិសេសអង្គជំនុំជម្រះ) មានកំហុស ក៏ប៉ុន្តែអំណះអំណាងរបស់គេចំពោះបញ្ហានេះមិនបានធ្វើការពិនិត្យអោយបានច្បាស់លាស់ណាមួយនោះទេ។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញានឹងដោះស្រាយបញ្ហាទាំងនេះជាមួយមេធាវីការពារក្តីនៅក្នុងដីកាសម្រេចដូចដែលបានលើកឡើង។

៣០- អំណះអំណាងទីមួយរបស់មេធាវីការពារក្តី គឺ "វិធាន២៥ ត្រូវបានដាក់ចំណងជើងជាទូទៅ "ការថតសម្លេង ឬរូបភាពក្នុងពេលសួរយកចម្លើយ" (ពុំមែន "ការថតសម្លេង ឬរូបភាពជនសង្ស័យ និងជនជាប់ចោទឡើយ"។ ចំណងជើងនេះឆ្លុះបញ្ចាំងថា វិធាននេះអនុវត្តចំពោះការស្តាប់ចម្លើយ *ទាំងអស់*"[48]។ ដោយទុកមួយឡែកនូវសំណួរស្តីពីថាតើគួរត្រូវផ្តល់ទម្ងន់នៃការបកស្រាយចំណងជើងប៉ុណ្ណានោះ វិធាន២៥ ទាំងមូល ត្រូវទាក់ទងជាមួយនឹង "ការស្តាប់ចម្លើយ *ទាំងអស់*"។ យ៉ាងណាក៏ដោយ វិធាន២៥.២ គ្រាន់តែជាបញ្ញត្តិមួយនៃវិធាន២៥ ដែលត្រូវអនុវត្តតែទៅលើជនសង្ស័យ និងជនជាប់ចោទតែប៉ុណ្ណោះ ដូចដែលបានពន្យល់រួចមកហើយ។ គ្រប់ "ជនដទៃទៀត" ទាំងអស់ ត្រូវបានលើកឡើងដោយវិធាន២៥.៤។ បន្ថែមលើនេះ ផ្អែកតាមភាពសមហេតុសមផលដែលថាមេធាវីការពារក្តីបានបន្តថា ចំណងជើងវិធានផ្ទៃក្នុង គឺមិនស្រដៀងគ្នាទៅនឹង "ការថតសម្លេងគ្រប់ការសួរចម្លើយទាំងអស់" នោះទេ។ ចំណងជើងនេះឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវថា វិធាននេះនឹងលើកឡើងពីការស្តាប់ចម្លើយណាដែលចាំបាច់ត្រូវថតសម្លេងតែប៉ុណ្ណោះ។

---

[47] ឯកសារលេខ **E234/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឲ្យ ក.ស.ច.ស ធ្វើការបញ្ជាក់ ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ឲ្យផ្តល់ភស្តុតាង ទាក់ទងនឹងការស្តាប់ចម្លើយនេះ", ថ្ងៃទី៨ ខែ តុលា ឆ្នាំ ២០១២, កថាខណ្ឌ ២៥, ២៦ (អត្ថបទដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[48] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ១១(ក)។

៣១- បន្ទាប់មកមេធាវីការពារក្តីបានខិតខំរកឲ្យឃើញនូវភាពផ្ទុយគ្នារវាងវិធាន២៥.១ និង ២៥.២ លើបីចំណុច ដែលជាការប៉ុនប៉ងយ៉ាងច្បាស់ក្រឡែត ដើម្បីបង្ហាញថាវិធាន២៥.២ ក៏អនុវត្តចំពោះសាក្សីផងដែរ។ ទីមួយ មេធាវីការពារក្តីអះអាងថា មិនដូចជាវិធាន២៥.២ នោះទេ វិធាន២៥.១ "*ពុំ* តម្រូវឲ្យជនសង្ស័យ /ជនត្រូវចោទ ចុះហត្ថលេខាលើសំណៅនៃចម្លើយរបស់ពួកគាត់[49]" មានន័យថា ការធ្វើដូច្នេះ យ៉ាងណានោះ ក៏បានបង្ហិធាន២៥.២ គួរអនុវត្តតែចំពោះការស្តាប់ចម្លើយសាក្សី ប៉ុន្តែមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ពីហេតុអ្វីនោះឡើយ។ ទោះបីជាសហព្រះរាជអាជ្ញាមិនបានយល់ស្របតាមកត្តភាពនៃការអះអាងនេះក៏ដោយ ក៏បានកត់សម្គាល់ឃើញថា វិធាន២៥.១ បានលើកឡើងពីកាលៈទេសៈដែលការសួរចម្លើយត្រូវបានថតសម្លេង ឬថតរូបភាព ហើយបានថ្លែងថាគេត្រូវតែប្រគល់សំណៅចម្លងនៃការថតសម្លេង ឬការថតរូបភាពទាំងនោះឲ្យទៅអ្នកត្រូវសួរចម្លើយ។ វិធាន២៥.២ បានលើកឡើងពីការសួរចម្លើយ "នៅពេលណាដែលកាលៈទេសៈរារាំងចំពោះការថតនេះ" ហើយហេតុដូច្នេះ កាលណាមានតែការថតការសួរចម្លើយ គឺកំណត់ហេតុជាលាយលក្ខណ៍អក្សរ គេត្រូវប្រគល់សំណៅចម្លងមួយច្បាប់ឲ្យទៅបុគ្គលដែលបានសួរចម្លើយនោះ។ ដូច្នេះទៅតាមវិធានទាំងពីរនេះ គឺវិធាន២៥.១ និង ២៥.២ ជនសង្ស័យ ឬជនត្រូវចោទដែលត្រូវបានសួរចម្លើយ ត្រូវបានគេប្រគល់ឲ្យនូវសំណៅចម្លងមួយ ច្បាប់ដ៏ល្អបំផុតដែលអាចមាននៃការថតការសួរចម្លើយ។ វិធានទាំងពីរនេះបានផ្តល់នូវជម្រើសពីរនៅក្នុងបរិបទប្រភេទដូចគ្នានៃការសម្ភាសន៍។

៣២- បន្ទាប់មក មេធាវីការពារក្តីបានអះអាងថា វិធាន២៥.១ បានប្រើយ៉ាងច្បាស់ក្រឡែត នៅក្នុងប្រយោគនូវពាក្យ "ជនសង្ស័យ និងជនត្រូវចោទ" រីឯវិធាន២៥.២ "ជនណាម្នាក់"[50]។ សហព្រះរាជអាជ្ញា បានពន្យល់រួចហើយអំពីមូលហេតុថា មានតែការបកស្រាយប្រកបដោយតក្កភាពនៃពាក្យ "ជនណាម្នាក់" គឺយោងសំដៅទៅដល់ "ជនសង្ស័យ និងជនត្រូវចោទ" ខាងលើនោះហើយ។

៣៣- ជាការញែកឲ្យឃើញពីភាពខុសគ្នាចុងក្រោយមួយ រវាងវិធាន២៥.១ និង ២៥.២ មេធាវីការពារក្តីបានអះអាងនោះ គឺថាវិធាន២៥.១ តម្រូវអោយធ្វើការសម្លេងនៅគ្រប់កាលៈទេសៈទាំងអស់។ "ប្រសិនបើវិធាន២៥.២ មានចេតនាអនុវត្តចំពោះជនសង្ស័យ/ជនត្រូវចោទ ការដែលវិធាននេះចែងថាជនណាម្នាក់ "អាច" ត្រូវបានសួរចម្លើយដោយពុំមានការថតសម្លេង ឬរូបភាព នឹងពុំមានអត្ថន័យខ្លឹមាសារ

[49] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ១១(ខ)។

[50] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ១១(គ)។

ឡើយ បើពិនិត្យអំពីលក្ខខណ្ឌតម្រូវនៃវិធាន២៥.១ ដែលថាការស្តាប់ចម្លើយ "ត្រូវតែ" ថតសម្លេង ឬរូបភាព"[51]។ ជាថ្មីម្តងទៀត នៅទីនេះ មេធាវីការពារក្តីបានសរសេរវិធានឡើងវិញក្នុងគោលបំណងដើម្បីធ្វើការព្យាយាមរកមើលការបំពានណាមួយ។ វិធាន២៥.១ មិនបាន "តម្រូវឱ្យមានការថតសម្លេង ឬរូបភាព នៅគ្រប់កាលៈទេសៈ*ទាំងអស់*" នោះទេ។ តាមរយៈពាក្យពេជន៍ដ៏ច្បាស់លាស់របស់វាគេតម្រូវឱ្យមានការថតសម្លេង ឬរូបភាព នៅពេល"ដែលអាចធ្វើទៅបាន"[52]។ ដូចដែលបានពន្យល់ពីមុនមករួចហើយ វិធាន២៥.២ គ្របដណ្តប់ទៅលើលកាលៈទេសៈណាដែលការសួរចម្លើយជនសង្ស័យ ឬជនត្រូវចោទណាម្នាក់ដែល "មិនអាច" ពីព្រោះ "កាលៈទេសៈរារាំងចំពោះការថតនេះ"[53]។ នៅក្នុងកាលៈទេសៈទាំងនោះ ជនសង្ស័យ ឬជនត្រូវចោទ "អាចត្រូវបានសួរយកចម្លើយដោយមិនចាំបាច់មានការថតសម្លេង ឬថតរូបភាព" ទេ។ ដូច្នេះ វាពុំមាន ភាពមិនស្របគ្នាឬមិនត្រូវគ្នាទាំងតក្កភាពសម ឬខាងភាសា រវាងបទប្បញ្ញត្តិទាំងពីរនៃវិធាន២៥ នោះឡើយ។ តាមពិត បទប្បញ្ញត្តិទាំងពីរនេះបានបង្គ្រប់ឱ្យគ្នាទៅវិញទៅមក។

៣៤- ការអះអាងបន្ទាប់មកទៀតរបស់មេធាវីការពារក្តីគឺ៖

> *ដូចដែល កសព បានលើកឡើង វិធាន២៥.៤ ពុំមែនជាវិធានដែលត្រូវបានចែងលើសដោយមិនចាំបាច់ឡើយ ប្រសិនបើវិធាន២៥.២ត្រូវបានបកស្រាយថាគឺអាចអនុវត្តចំពោះជនដែលត្រូវបានសួរយកចម្លើយទាំងអស់។ វិធាន២៥.៤ គ្រាន់តែចែងថា "សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត អាចជ្រើសរើសអនុវត្តតាមនីតិវិធីក្នុងវិធាននេះ នៅពេលសួរសំណួរបុគ្គលផ្សេងៗ ក្រៅពីបុគ្គលទាំងឡាយដូចដែលបានរៀបរាប់ខាងលើ..."។ នេះមានន័យថានីតិវិធីដូចមានចែង ក្នុងធាន២៥.១ (ដូចជាការផ្តល់កំណត់ហេតុមួយច្បាប់ទៅសាក្សី) អាចជាជម្រើស ដោយពុំមានការចាប់បង្ខំនៅពេលមានការស្តាប់ចម្លើយសាក្សីទាំងអស់ ពុំមែនត្រឹមតែជនសង្ស័យ/ជនត្រូវចោទឡើយ។ វាពុំប៉ះពាល់ដល់វិធាន២៥.២ ឡើយ*[54]។

---

[51] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ១១(ឃ) (គូសបញ្ជាក់បន្ថែមក្នុងសំណៅដើម)។

[52] វិធាន ២៥(១)។

[53] វិធាន ២៥(២)។

[54] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ១១(ង) (អត្ថបទដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

៣៥- ជាការឆ្លើយតប សហព្រះរាជអាជ្ញាកត់សម្គាល់ថាវិធាន២៥.២ គឺ “នៅពីលើ” វិធាន២៥.៤ ហើយចំណុចពីមុនរបស់វាដែលថាវិធាន២៥.៤ ត្រូវបានចាត់ទុកថាគ្មានភាពចាំបាច់ ដោយការបកស្រាយវិធាន២៥.២ ដើម្បីអនុវត្តចំពោះគ្រប់ជនទាំងអស់ ដែលត្រូវបានបដិសេធដោយអំណះអំណាងរបស់មេធាវីការពារក្តី។

៣៦- ចុងបញ្ចប់ មេធាវីការពារក្តីបានពន្លឿនការអះអាងចំនួនបីទាក់ទងទៅនឹងគោលការណ៍នៃការបកស្រាយដែលពួកគេបានអះអាងថាមានការគាំទ្រដល់ការអនុវត្តវិធាន២៥.២ ចំពោះសាក្សីទល់នឹងការអនុវត្តចំពោះជនសង្ស័យ ឬជនត្រូវចោទ។ មុនដំបូង មេធាវីការពារក្តីបានអះអាងថា វិធាន២១ គាំទ្រដល់ការបកស្រាយរបស់ខ្លួននៅលើវិធាន២៥ ពីព្រោះថា “ប្រសិនបើវិធាន២៥.៤ ត្រូវបានអានដើម្បីផ្តល់ជម្រើសដល់ កសចស ក្នុងការធ្វើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វានឹងពុំធានាបានតម្លាភាព ឬពុំគាំពារផលប្រយោជន៍របស់លោក អៀង សារី ដូចតាមការតម្រូវ នៃវិធាន២១ ឡើយ”[55]។ សេចក្តីណែនាំបកស្រាយវិធាន២១ មិនអាចចូលជំនួសការអានសមហេតុសមផលនៃវិធាន២៥ បានឡើយ។ ការអានដ៏សមហេតុសមផល គឺមានតែការអានដែល សហព្រះរាជអាជ្ញាបានជំរុញទៅមុខសម្រាប់ហេតុផលនានាដែលបានថ្លែងពីមុនមករួចហើយប៉ុណ្ណោះ។ បន្ថែមលើនេះ មេធាវីការពារក្តីមិនបានបង្ហាញអ្វីសោះពីតម្លាភាព ហើយ “ផល ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដោយគិតដល់លក្ខណៈពិសេសរបស់ អវតក”[56] ក៏មិនត្រូវបានការពារឲ្យបានគ្រប់គ្រាន់ដោយវិធានផ្ទៃក្នុងដូច ដែលគេបានសរសេរវានោះដែរ ជាជាងដូចអ្វីដែលមេធាវីការពារក្តីចង់ឲ្យគេធ្វើការបកស្រាយវាឡើងវិញនោះទេ។

៣៧- បន្ទាប់មក មេធាវីការពារក្តីបានអះអាងថា “វិធាន២៥.២ មានភាពច្បាស់លាស់ និងគួរត្រូវបាន អនុវត្តដោយយោងទៅតាមភាសាដ៏សាមញ្ញរបស់វិធាននេះ។ លទ្ធផលខុសទំនងនឹងពុំមានឡើយ តាមរយៈការបកស្រាយថាវិធាន២៥.២ អនុវត្តចំពោះជនដែលត្រូវស្តាប់យកចម្លើយទាំងអស់”[57]។ *សម្រាប់គោលបំណងវែកញែក (arguendo),* សូម្បីតែការសន្មតដែលថាច្បាប់បានពិនិត្យឡើងវិញនូវមាត្រាដែលមេធាវីការពារក្តីបានលើកឡើងសម្រាប់គោលការណ៍នេះ គឺមានលក្ខណៈចាប់បង្ខំ នោះគឺវិធាន២៥ ដែលត្រូវបានអានទាំងស្រុងថា មានភាពច្បាស់លាស់នៅក្នុងវិធាន២៥.២ ដែលអនុវត្តចំពោះតែជន

[55] ឯកសារលេខ **E241** សំណើ ត្រង់កថាខណ្ឌ ១១(ច)។

[56] វិធាន ២១(១)។

[57] ឯកសារលេខ **E241** សំណើ កថាខណ្ឌ ១១(ឆ)។

សង្ស័យ និងជនត្រូវចោទប៉ុណ្ណោះ។ លទ្ធផលដែលមិនទំនងមុខជានឹងមានកើតឡើង ប្រសិនបើវិធាន ២៥.២ ត្រូវបានគេបកស្រាយដូចដែលមេធាវីការពារក្តីបានផ្តល់ប្រឹក្សានោះ ដោយសារមូលហេតុដែលថាវិធាន២៥.៤ មុខជានឹងត្រូវបានចាត់ទុកថាមានភាពចាំបាច់ ជាមិនខាន ដូចដែលបានពន្យល់នៅខាងលើស្រាប់។

៣៨- អំណះអំណាងទីបី និងជាចុងក្រោយ ដែលត្រូវបានបកស្រាយនោះគឺ "ប្រសិនបើមានមន្ទិលណាមួយអំពីការបកស្រាយត្រឹមត្រូវអំពីវិធាន២៥ មន្ទិលនេះត្រូវតែដោះស្រាយដោយផ្តល់ប្រយោជន៍ទៅជនជាប់ចោទ ដោយអនុលោមតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជន ជាប់ចោទ (in dubio pro reo) ដែលជាគោលការណ៍សារវ័ន្តនៃច្បាប់ព្រហ្មទណ្ឌដែលត្រូវបាន ទទួលស្គាល់ដោយមាត្រា៣៨នៃរដ្ឋធម្មនុញ្ញ*"[58]។ ដោយហេតុថាមានតែការបកស្រាយដ៏សមហេតុសមផល ដែលសហព្រះរាជអាជ្ញាបានធ្វើការពន្យល់នៅលើវិធាន២៥ប៉ុណ្ណោះ ដែលពុំមាន "មន្ទិល" ណាមួយដែលត្រូវដោះស្រាយតាមគោលការណ៍នេះជាមធ្យោបាយនោះឡើយ។ បន្ថែមលើនេះ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានថ្លែងនៅក្នុងសេចក្តីសម្រេច ដែលបានលើកឡើងដោយ មេធាវីការពារក្តីថា៖

> *ចំពោះគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អាចអនុវត្តបានចំពោះស្ថានភាពលំបាកនៃអត្ថន័យច្បាប់ គោលការណ៍នេះ ត្រូវកម្រិតត្រឹមតែភាពមន្ទិលសង្ស័យដែលនៅតែមាន ក្រោយការបកស្រាយ។ ហេតុដូច្នេះ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវតែអនុវត្តយ៉ាងត្រឹមត្រូវចំពោះភាពមន្ទិលសង្ស័យអំពីខ្លឹមសារនៃបទដ្ឋានគតិយុត្តិដែលនៅតែមាន ក្រោយការអនុវត្តនូវវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយធ្វើការពិចារណាលើពាក្យពេចន៍នៃបទប្បញ្ញត្តិការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ។ ដូចនេះ តាមការអនុវត្តជាក់ស្តែង គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ នឹងមិនមានភាពចាំ*

[58] ឯកសារលេខ **E241** សំណើ កថាខណ្ឌ ១១(ជ)

*បាច់ ក្នុងការដោះស្រាយទៅលើភាពខ្វះចន្លោះនៃច្បាប់ឡើយ ប៉ុន្តែ អាចនឹងដើរតួនាទីក្នុងករណីដែលមានវិវាទបទដ្ឋានច្បាប់នានា*[59]។

៣៩- ការណ៍នេះ មិនមែនជាព្រឹត្តិការណ៍មួយក្នុងចំណោមព្រឹត្តិការណ៍ដ៏កម្រនានា ស្តីពីការប៉ះទង្គិចគ្នានៃបទដ្ឋាននោះទេ។ តាមពិត វាមិនមែនជាស្ថានភាពមួយដែលនៅមានការមន្ទិលសង្ស័យ បន្ទាប់ពីមានការស្នើសុំឱ្យមានមធ្យោបាយក្នុងការបកស្រាយដទៃទៀត ដូចដែលសហព្រះរាជអាជ្ញាធ្លាប់បានពន្យល់ពីមុនមករួចហើយ។

## III. **សេចក្តីសន្និដ្ឋាន**

៤០- សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើនេះ

ក. ស្វែងរកការប្តឹងឡើងវិញអំពីបញ្ហានីតិវិធីដែលបានសម្រេចរួចហើយដោយអង្គជំនុំជម្រះ

ខ. ផ្តល់នូវការបកស្រាយវិធានពាក់ព័ន្ធនានាផ្ទុយនឹងស្មារតី និងខ្លឹមសាររបស់វិធានទាំងនោះ

គ. ត្រូវបានរារាំងដោយវិធាន៧៦(៧)

ឃ. ខកខានមិនបានពន្យល់ភាពខ្វះចន្លោះរបស់មេធាវីការពារក្តីចំពោះការកង្វល់ ដែលបានសន្មតរបស់ខ្លួនស្តីពីកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងកិច្ចស៊ើបសួររបស់តុលាការដែលមានរយៈពេល៣ឆ្នាំហើយ

ង. ក្នុងកាលៈទេសៈណាក៏ដោយ ខកខានមិនបានបង្ហាញពីការរំលោភណាមួយទៅលើវិធានផ្ទៃក្នុង មិនបានបង្ហាញពីការជ្រៀតជ្រែកណាមួយទៅលើភ័ស្តុតាង ឬមិនបានបង្ហាញពីការរំលោភទៅលើសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបាននូវការកាត់ក្តីដោយត្រឹមត្រូវ ដែលភ្ជាប់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចាត់វិធានការការស៊ើបសួរបន្ថែម តាមវិធាន៩៣ ឬដើម្បីពន្លាតពេលវេលាកំណត់របស់ខ្លួន និងធនធានតុលាការ ដោយធ្វើសវនាការ ជាសាធារណៈ។

៤១- ការលើកឡើងចោទប្រកាន់ដែលមិនប្រកបដោយសុភវិនិច្ឆ័យ និងដែលមានលក្ខណៈទូទៅ របស់មេធាវីការពារក្តី ស្តីពីភាពមិនត្រឹមត្រូវរបស់ កសចស គួរតែត្រូវបានច្រានចោល។ មេធាវីការពារក្តីមាន

[59] ឯកសារលេខ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១, កថាខណ្ឌ ៣១។

សេរីភាព នៅក្នុងការប្រើប្រាស់ធនធានរបស់ខ្លួនឲ្យអស់លទ្ធភាព ដូចដែលអង្គជំនុំជម្រះផ្តល់ឲ្យ ដើម្បីធ្វើសេចក្តីសន្និដ្ឋានអំពីតម្លៃភាវនីយភាពចំពោះភ័ស្តុតាងនៅក្នុងសំណុំរឿង។

៤២- សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា សំណើនេះគួរតែត្រូវបានបដិសេធចោលទាំងស្រុង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |